# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០១ សរ

## សារាចរ

## ស្តីពី

## ការទប់ស្កាត់អំពើអនាធិបតេយ្យ

## នៅតំបន់សៀមរាប-អង្គរ

កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាមានមោទនភាព ដោយបានទទួលការកោតសរសើរពីមជ្ឈដ្ឋានជាតិ និង អន្តរជាតិ ចំពោះឆន្ទៈនិងការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួន ក្នុងការអនុវត្តគោលនយោបាយស្តីពីការអភិរក្សនិងការអភិវឌ្ឍតំបន់សៀមរាប-អង្គរ ។ ជារួម យើងបានលុបបំបាត់ចោលនូវការបំផ្លិចបំផ្លាញ ការលួចសម្បត្តិវប្បធម៌ស្ទើរតែទាំងអស់ពីតំបន់អង្គរ បានធ្វើការងារទ្រទ្រង់និងជួសជុលប្រាសាទដែលទ្រុឌទ្រោមមួយចំនួន ការពារប្រាសាទនិងបរិស្ថានបានល្អ រៀបចំ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមួយចំនួនសំរាប់ភ្ញៀវទេសចរ និង ធានាបានទាំងស្រុងនូវសុខសុវត្ថិភាពដល់បងប្អូនប្រជាពលរដ្ឋក៏ដូចភ្ញៀវទេសចរ ពោលគឺ យើងបានដំណើរការ ការពារ អភិរក្សប្រាសាទផង និងអភិវឌ្ឍតំបន់អង្គរ ជំរុញការរីកចំរើនខាងវិស័យទេសចរណ៍ ព្រោះថាអង្គរជាបេះដូងនៃការអភិវឌ្ឍទេសចរណ៍វប្បធម៌កម្ពុជា ។

ប៉ុន្តែរយៈពេលចុងក្រោយនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅតំបន់សៀមរាប-អង្គរ ក៏មានការកើតឡើងវិញនូវ បាតុភាពអនាធិបតេយ្យគួរឱ្យព្រួយបារម្ភ ដែលបង្កឡើងដោយក្រុមជនមួយចំនួនតូច បណ្តាលឱ្យមានការប៉ះពាល់ដល់ដំណើរការ ការពារ និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់រមណីយដ្ឋាន សៀមរាប-អង្គរ ។

ភាពអនាធិបតេយ្យទាំងនោះរួមមាន ការលួចនិងការបំផ្លាញវត្ថុបុរាណ ការកាប់ព្រៃទន្ទ្រានយកដី ការរំលោភយកដីធ្វើជាកម្មសិទ្ធិ ការប្រកាសផ្សាយទិញលក់ដី និង ការតាំងតូបលក់ដូរក្នុងតំបន់ហាមឃាត់ ការសាងសង់សំណង់ផ្សេងៗនៅក្នុងរមណីយដ្ឋានអង្គរ ដែលជាតំបន់ត្រូវបានហាមឃាត់និងត្រូវបានការពារដោយច្បាប់ ។

ដើម្បីទប់ស្កាត់នូវអំពើអនាធិបតេយ្យខាងលើ ជាពិសេសក្នុងគោលដៅបន្តការការពារថែរក្សាសម្បត្តិវប្បធម៌ជាតិ និងធម្មជាតិនៅឧទ្យានអង្គរ ដែលជាអចលនទ្រព្យសម្បត្តិរដ្ឋ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម :

១. អាជ្ញាធរអប្សរា ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយថែមទៀតដល់ប្រជាពលរដ្ឋ នូវព្រះរាជក្រឹត្យលេខ ០០១ នស.ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និង ការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ

និងត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និង អាជ្ញាធរមូលដ្ឋាន ដើម្បីចាត់វិធានការការពារសម្បត្តិវប្បធម៌ជាតិ និង ធម្មជាតិឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ចំពោះគណៈកម្មការចម្រុះ ស្តីពីការទប់ស្កាត់អំពើអនាធិបតេយ្យក្នុងឧទ្យានអង្គរ ដែលបានបង្កើតឡើងតាមដីកាសាលាខេត្តសៀមរាបលេខ ០១៤ សសរ  ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលតាមរយៈ អាជ្ញាធរអប្សរា នូវការវិវត្តក្នុងតំបន់នោះជារៀងរាល់ខែ ។

**២. ក្រសួងការពារជាតិ និង អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ** ត្រូវចេញបទបញ្ជាដល់អង្គភាព ដែលឈរជើងនៅទីនោះ ឱ្យជួយទប់ស្កាត់អំពើអនាធិបតេយ្យខាងលើ ។

**៣. ក្រសួងមហាផ្ទៃ និង អគ្គស្នងការដ្ឋាននគរបាលជាតិ** ត្រូវធ្វើការណែនាំជាបន្ទាន់ដល់អាជ្ញាធរដែនដី និងកងកម្លាំងនគរបាលប្រចាំការនៅមូលដ្ឋាន   ឱ្យបង្កើនការយកចិត្តទុកដាក់ខ្ពស់ដល់ការការពារសន្តិសុខសណ្តាប់ធ្នាប់ ការការពារបេតិកភណ្ឌជាតិ  សុវត្ថិភាពដល់ភ្ញៀវទេសចរ  និងធ្វើការណែនាំដល់ប្រជាពលរដ្ឋដើម្បីបញ្ឈប់ការកាប់ព្រៃ ទន្ទ្រានយកដីមកធ្វើជាកម្មសិទ្ធិ និងឱ្យជួយចូលរួមសហការការពារសម្បត្តិវប្បធម៌ជាតិ និងធម្មជាតិ នៅតំបន់សៀមរាប-អង្គរ ។

**៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន** ត្រូវធ្វើការណែនាំដល់មន្ត្រីក្រោមឱវាទ ដោយសហការជាមួយ  អាជ្ញាធរអប្សរា  កម្លាំងមានសមត្ថកិច្ច  និង  អាជ្ញាធរដែនដី  ដើម្បីបង្កើនការការពារឱ្យបានម៉ឺងម៉ាត់ជាទីបំផុតនៅតំបន់នោះ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរអប្សរា អាជ្ញាធរដែនដី  ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០៣

ហ៊ុន សែន

ចម្លងជូន :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និង ខេត្ត-ក្រុង

-កាលប្បវត្តិ-ឯកសារ